**សម្ព័ន្ធជនអន្តោប្រវេសន៍នៃរដ្ឋរ៉ូតអាយលែន (IMMIGRANT COALITION OF RHODE ISLAND)**

# បន្ទុកសាធារណៈ

*មានរឿងចំនួន 4 ដែលអ្នកត្រូវការដឹង*

ខែតុលា 2022

មនុស្សមួយចំនួនដែលដាក់ពាក់សុំប័ណ្ណបៃតង ឬទិដ្ឋាការដើម្បីចូលទៅកាន់សហរដ្ឋអាមេរិក ត្រូវតែជាប់ការធ្វើតេស្ត "បន្ទុកសាធារណៈ"។ ក្នុងករណីទាំងនោះ មន្ត្រីអន្តោប្រវេសន៍ពិនិត្យមើលថាតើបុគ្គលម្នាក់នឹងពឹងផ្អែកភាគច្រើនទៅលើរដ្ឋាភិបាលសម្រាប់ការជួយឧបត្ថម្ភនៅពេលអនាគតដែរឬអត់។ រឿងសំខាន់បួនយ៉ាងដែលគ្រួសារជនអន្តោប្រវេសន៍ចាំបាច់ត្រូវដឹងអំពីបន្ទុកសាធារណៈ គឺមានដូចជា៖

## 1 វិធានបន្ទុកសាធារណៈដ៏តឹងរឹងរបស់លោកត្រាំ ត្រូវបានផ្លាស់ប្តូរ

រដ្ឋបាលលោកបៃដិន បានបញ្ចប់វិធានស្តីពីបន្ទុកសាធារណៈឆ្នាំ2019 ដែលបានដាក់ឲ្យអនុវត្តដោយរដ្ឋបាលរបស់លោកត្រាំ។ ផ្នែកសេវាសញ្ជាតិសហរដ្ឋអាមេរិក និងសេវាអន្តោប្រវេសន៍ (U.S.Citizenship and Immigration Services, USCIS) បានប្រើប្រាស់ឡើងវិញនូវគោលនយោបាយបន្ទុកសាធារណៈឆ្នាំ1999 ដែលមានជាយូរណាស់មកហើយ។ **ជនអន្តោប្រវេសន៍អាចទទួលបានអត្ថប្រយោជន៍ផ្នែកសុខភាព អាហារូបត្ថម្ភ និងលំនៅដ្ឋានសំខាន់ៗ ដោយពុំមានភ័យខ្លាចអំពីផលប៉ះពាល់ជាអវិជ្ជមានទៅលើស្ថានភាពអន្តោប្រវេសន៍នោះទេ។**

## 2 មនុស្សភាគច្រើនមិនចាំបាច់ព្រួយបារម្ភអំពីបន្ទុកសាធារណៈឡើយ

បន្ទុកសាធារណៈអនុវត្តតែនៅពេលណាបុគ្គលម្នាក់កំពុងស្វែងរកប័ណ្ណបៃតងតាមរយៈសមាជិកគ្រួសារណាម្នាក់ ឬចង់ចូលទៅកាន់សហរដ្ឋអាមេរិកពីខាងក្រៅប្រទេសតែប៉ុណ្ណោះ។ វា **មិនអនុវត្តទេ** ពេលណាជនភៀសខ្លួន ឬអ្នកស្វែងរកសិទ្ធិជ្រកកោន ដាក់ពាក្យសុំប័ណ្ណបៃតង ឬនៅពេលដែលអ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ (Lawful Permeant Resident, LPR) ណាម្នាក់ព្យាយាមក្លាយជាពលរដ្ឋអាមេរិក។

## 3 អត្ថប្រយោជន៍រដ្ឋាភិបាលភាគច្រើនមិនរាប់បញ្ចូលឡើយ

មានតែអត្ថប្រយោជន៍រដ្ឋាភិបាលតែ 2 ប្រភេទប៉ុណ្ណោះ ត្រូវបានពិចារណា៖

1. ការឧបត្ថម្ភជាសាច់ប្រាក់ប្រចាំខែ - ចំណូលរបបសន្តិសុខបន្ថែម (Supplemental Security Income, SSI) និងអត្ថប្រយោជន៍ RI Works។
2. ការថែទាំនៅមណ្ឌលថែទាំរយៈពេលវែងដែលបង់ប្រាក់ដោយ Medicaid។

មន្ត្រីអន្តោប្រវេសន៍ **មិនអាច** ពិនិត្យមើលអត្ថប្រយោជន៍ផ្សេងទៀតណាមួយដែលអ្នកអាចបានទទួល ដូចជា SNAP, Medicaid, Child Care Assistance ឬលំនៅដ្ឋានដែលបានផ្តល់ជំនួយឧបត្ថម្ភ។ ប្រសិនបើអ្នកបានដាក់ពាក្យសុំអត្ថប្រយោជន៍សម្រាប់សមាជិកគ្រួសារណាម្នាក់ (ឧទាហរណ៍ ឪពុកម្តាយដាក់ពាក្យសុំ RI Works សម្រាប់កូនរបស់ខ្លួន) ការណ៍នេះក៏មិនត្រូវបានរាប់បញ្ចូលផងដែរ។

## 4 បន្ទុកសាធារណៈមិនមែនត្រឹមតែជាអត្ថប្រយោជន៍រដ្ឋាភិបាលនោះទេ

**មន្ត្រីអន្តោប្រវេសន៍ ត្រូវតែពិនិត្យមើលជារួមទៅលើបុគ្គលម្នាក់ មិនមែនគ្រាន់តែមើលថាតើបុគ្គលម្នាក់បានប្រើប្រាស់អត្ថប្រយោជន៍របស់រដ្ឋាភិបាលនោះទេ។** នោះរាប់ទាំងថាតើសមាជិកគ្រួសារម្នាក់ ឬបុគ្គលម្នាក់ទៀតដែលមានប្រាក់ចំណូលឬធនធានគ្រប់គ្រាន់ បានសន្យាជួយឧបត្ថម្ភអ្នកដែរឬទេ។ "ការធានាអះអាងលើការជួយឧបត្ថម្ភ" នោះ និងកត្តាវិជ្ជមានផ្សេងទៀត អាចនឹងមានអត្ថប្រយោជន៍ ទោះបីជាអ្នកបានប្រើប្រាស់កម្មវិធីរបស់រដ្ឋាភិបាលកាលពីមុនមកក៏ដោយ។ នៅក្នុងករណីភាគច្រើន ការប្រើប្រាស់កម្មវិធីរដ្ឋាភិបាលនឹងមិនប៉ះពាល់ដល់ពាក្យសុំអន្តោប្រវេសន៍នោះទេ។

---

ប្រសិនបើអ្នកមានបន្ទុកសាធារណៈ ឬក្តីកង្វល់អន្តោប្រវេសន៍ផ្សេងទៀត សូមទាក់ទងទៅកាន់វិទ្យាស្ថានអន្តរជាតិ Dorcas International Institute៖ 401-784-8607 ឬទាក់ទងទៅកាន់ Progreso Latino: 401-728-5920

រៀបរៀងដោយវិទ្យាស្ថានវឌ្ឍនភាពសេដ្ឋកិច្ច និងការការពារគ្រួសារជនអន្តោប្រវេសន៍ (Economic Progress Institute & Protecting Immigrant Families)